ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរទន្លេសាប

លេខ :......៦០៦......អទស

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងាររៀបចំផែនការបច្ចេកទេស និងចុះសិក្សាលម្អិតអំពីសណ្ឋានបាតបឹងទន្លេសាបរួមជាមួយសក្តានុពល និងលទ្ធភាពនៃស្ទឹងសំខាន់ៗទាំង១១ នៅជុំវិញបឹងទន្លេសាប

## រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- យោងលិខិតលេខ ២០៤៤ សជណ.កធ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់អាជ្ញាធរទន្លេសាប

# **សម្រេច**

**ប្រការ ១.**_

ត្រូវបានបង្កើតក្រុមការងាររៀបចំផែនការបច្ចេកទេស និងចុះសិក្សាលម្អិត អំពីសណ្ឋានបាតបឹងទន្លេសាប រួមជាមួយសក្តានុពល និងលទ្ធភាពនៃស្ទឹងសំខាន់ៗទាំង១១ នៅជុំវិញបឹងទន្លេសាប ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តម | **ម៉ៅ** | **ហាក់** | អនុប្រធាន អាជ្ញាធរទន្លេសាប | ប្រធាន |
| ២- | ឯកឧត្តម | **សរ** | **គឹមសាន្ត** | អគ្គលេខាធិការ អាជ្ញាធរទន្លេសាប | អនុប្រធាន |
| ៣- | ឯកឧត្តម | **ជា** | **សុខនី** | អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប | សមាជិក |
| ៤- | លោក | **ឡុក** | **សីលា** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៥- | លោក | **ទិន** | **ម៉ុនពៅ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៦- | លោក | **ម៉ុន** | **ទុឌ្ឍី** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧- | លោកស្រី | **ប្រាក់** | **ចាន់វឌ្ឍនា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៨- | លោក | **អ៊ាម** | **បញ្ញាវឌ្ឍន៍** | ប្រធានការិយាល័យ | សមាជិក |
| ៩- | លោក | **ឡុញ** | **ណារិន្ទ** | ប្រធានការិយាល័យ | សមាជិក |
| ១០- | លោក | **អៀ** | **ច័ន្ទរិទ្ធ** | អនុប្រធានការិយាល័យ | សមាជិក |
| ១១- | នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ នៃក្រសួងធនធានទឹក និងឧតុនិយម | | | | សមាជិក |
| ១២- | នាយកដ្ឋានគ្រប់គ្រងព័ត៌មាន និងចំណេះដឹង នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | | | | សមាជិក |

**ប្រការ ២.**_

ក្រុមការងារមានភារកិច្ច ដូចខាងក្រោម ៖

- សម្របសម្រួលកិច្ចការបច្ចេកទេសជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការងាររៀបចំផែនការបច្ចេកទេស សិក្សាលម្អិត អំពីសណ្ឋានបាតបឹងទន្លេសាប រួមជាមួយសក្តានុពល និងលទ្ធភាពនៃស្ទឹងសំខាន់ៗទាំង១១ នៅជុំវិញបឹងទន្លេសាប
- រៀបចំផែនការ និងធ្វើការសិក្សាលម្អិតសណ្ឋានបាតបឹងទន្លេសាប រួមជាមួយសក្តានុពល និងលទ្ធភាពនៃស្ទឹងសំខាន់ៗទាំង១១ នៅជុំវិញបឹងទន្លេសាប
- រៀបចំរបាយការណ៍វឌ្ឍនភាពការអនុវត្តគម្រោងជូនឯកឧត្តមប្រធាន ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ណែនាំ
- រៀបចំប្រមូលចងក្រងទិន្នន័យព័ត៌មានអំពីលទ្ធផលនៃគម្រោងចុះសិក្សាលម្អិត អំពីបាតបឹងទន្លេសាប រួមជាមួយសក្តានុពល និងលទ្ធភាពនៃស្ទឹងសំខាន់ៗទាំង១១ នៅជុំវិញបឹងទន្លេសាប ជូនឯកឧត្តមប្រធាន ពិនិត្យ សម្រេច
- បំពេញភារកិច្ចផ្សេងៗទៀតដែល ឯកត្តមប្រធានអាជ្ញាធរទន្លេសាប ប្រគល់ជូន។

**ប្រការ ៣.**_

ក្រុមការងារមានសិទ្ធិប្រើប្រាស់មន្ត្រីបច្ចេកទេសបន្ថែមទៀតយោងតាមការចាំបាច់ជាក់ស្តែង។

**ប្រការ ៤.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥._**

អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ទីប្រឹក្សា គ្រប់ប្រធាននាយកដ្ឋានចំណុះឱ្យអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៧កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ ២០២៥

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**
**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**ថោ_ជេដ្ឋា**

**ចម្លងជូន ៖** ៤

- ក្រសួងធនធានទឹក និងឧតុនិយម
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ
- នាយដ្ឋានគ្រប់គ្រងព័ត៌មាន និងចំណេះដឹង
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ